ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✽៥

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ១៥០១ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់គុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារក្នុងមណ្ឌល
- បានឃើញប្រកាសលេខ ១៥៨ ស.អ.យ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍
- បានឃើញប្រកាសលេខ ១២២៨ ស.អ.យ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព និងតួនាទី ភារកិច្ចរបស់ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារ[illegible] និងកុមារងាយរងគ្រោះ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

- បានឃើញសេចក្តីសម្រេចស្តីពីសមាសភាព និងមុខងារនៃអនុគណៈកម្មាធិការស្វែងរកការគាំទ្រ (អ.ស.គ) របស់ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ (កជករ) លេខ ១៣ ស.អ.យ/ក.ជ.ក.រ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០១១
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់អំពីការទទួលស្គាល់គុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ សម្រាប់ផ្តល់ជូនស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានអនុវត្តតាមគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅអនុវត្តនូវតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលធ្វើការពាក់ព័ន្ធនឹងកុមារ តាមនីតិវិធី គោលការណ៍បានកំណត់ ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពចំពោះស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលបានចុះកិច្ចព្រមព្រៀង ឬទទួលការអនុញ្ញាតឱ្យផ្តល់សេវា ការពារ ថែទាំ និងគាំទ្រកុមារពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ប្រការ ៤.-**

ស្ថាប័ននិងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលធ្វើការពាក់ព័ន្ធនឹងការផ្តល់សេវាការពារ ថែទាំ និងគាំទ្រកុមារ ត្រូវមានលក្ខណសម្បត្តិ ៩ ចំណុចដូចខាងក្រោម :

***១-គោលនយោបាយការពារកុមារសម្រាប់ប្រតិបត្តិក្នុងអង្គការ ត្រូវមាន:***

- ឯកសារគោលនយោបាយការពារកុមារជាភាសាខ្មែរងាយយល់
- បញ្ជីឈ្មោះអ្នកបានរៀនសូត្រ និងយល់ដឹងអំពីគោលនយោបាយ
- បញ្ជីឈ្មោះអ្នកបានចូលរួមរៀបចំគោលនយោបាយ
- របាយការណ៍ស្តីពីការទទួលស្គាល់គោលនយោបាយពីក្រុមប្រឹក្សាភិបាលរបស់អង្គការ
- សេចក្តីកំណត់អំពីការដោះស្រាយលើករណីរំលោភបំពានដែលអាចកើតមានក្នុងអង្គការ និងកាលវិភាគដែលត្រូវពិនិត្យមើលឡើងវិញ ។

***២- ការរាយការណ៍នឹងការឆ្លើយតបអំពីកង្វល់របស់កុមារ ត្រូវមាន:***

- ឯកសារស្តីពីនីតិវិធីក្នុងការរៀបចំ ឬការណែនាំពីការរាយការណ៍
- តារាងបង្ហាញពីជំហាននៃការការពារកុមារ
- ការបង្ហាញឈ្មោះ ព្រមទាំងតួនាទី និងភារកិច្ចរបស់ភ្នាក់ងារទទួលបន្ទុក
- ទម្រង់ឯកសារសម្រាប់កត់ត្រារបាយការណ៍អំពីសកម្មភាពការពារកុមារ ពេលមានហេតុការណ៍កើតឡើង ។

***៣- ការជ្រើសរើសបុគ្គលិក និងការចាត់ប្រមាណអំពីការប្រឈមមុខនឹងគ្រោះថ្នាក់របស់កុមារ ត្រូវមាន:***

- ឯកសារបង្ហាញពីរបៀបជ្រើសរើសបុគ្គលិក
- ឯកសារគំរូពាក្យស្នើសុំ ការធានាអះអាង និងលិខិតបញ្ជាក់ផ្សេងៗរបស់បេក្ខជន

- ភស្តុតាងបង្ហាញពីអ្នកដែលបានទាក់ទងជាមួយ ឬការបញ្ជាក់ពីអាកប្បកិរិយា និងលិខិតផ្តោលទោសរបស់បេក្ខជន
- ឯកសារដែលពន្យល់ពីរបៀបដែលអ្នកធានាអះអាង ពិភាក្សាដោយសម្ងាត់ជាមួយមន្ត្រីគ្រប់គ្រង អំពីអាកប្បកិរិយារបស់បេក្ខជនចំពោះកុមារ និងព័ត៌មានផ្សេងទៀតអំពីនីតិវិធីនេះ
- ឧបករណ៍ (ឯកសារណែនាំឬការគ្រប់គ្រងការប្រឈមនឹងគ្រោះថ្នាក់) សម្រាប់ជាជំនួយក្នុងការកំណត់ពីគ្រោះថ្នាក់ដល់កុមារក្នុងការរៀបចំផែនការសកម្មភាពជាមួយកុមារ និងការបង្កើតសេចក្តីណែនាំសម្រាប់ការពារកុមារឱ្យមានសុវត្ថិភាព
- គំរូជាឧបករណ៍ក្នុងការដឹកនាំកុមារទៅធ្វើទស្សនកិច្ចសិក្សា ឬប្រជុំជាដើម ។

## ៤- ក្រមសីលធម៌ ឬសេចក្តីណែនាំអំពីឥរិយាបថចំពោះកុមារ ត្រូវមាន:

- សេចក្តីណែនាំសម្រាប់ឥរិយាបថនៃមនុស្សធំធ្វើចំពោះកុមារ និងឥរិយាបថរបស់កុមារធ្វើចំពោះកុមារដទៃទៀត
- សេចក្តីណែនាំអំពីទំនាក់ទំនងផ្លូវកាយ ។

## ៥- ការទទួលខុសត្រូវទៅតាមផ្លូវច្បាប់ ត្រូវមាន:

- ឯកសារបង្ហាញពីការអនុវត្តដែលសមស្របតាមផ្លូវច្បាប់ (ដូចជាលិខិតធានាខុសត្រូវសម្រាប់ការចូលរួមរបស់កុមារ ការស្នាក់នៅ ការបញ្ជូន ឬការផ្ទេរកុមារ ការចុះស្រង់ព័ត៌មាន ការថត និង ការប្រើប្រាស់រូបភាពកុមារ ។ល ។) ។

## ៦- សម្ភារៈអប់រំ ព័ត៌មាន និងទំនាក់ទំនង ត្រូវមាន:

- ធនធាន និងសម្ភារៈជាឧបករណ៍ សម្រាប់លើកទឹកចិត្តដល់ការស្តាប់ និងការចូលរួមរបស់កុមារ ព្រមទាំងការទំនាក់ទំនងតាមវិធីសាស្ត្រផ្សេងៗ
- ព័ត៌មានស្តីអំពីអ្នកទទួលខុសត្រូវទីកន្លែងដែលកុមារត្រូវទៅ និងមធ្យោបាយសម្រាប់ទាក់ទងនៅពេលដែលពួកគេមានការបារម្ភ ។ អ្នកដែលទទួលខុសត្រូវនេះគួរតែជាមនុស្សដែលខុសពីអ្នកដែលទាក់ទងនឹងរឿងរ៉ាវក្នុងពាក្យបណ្តឹង
- ឯកសារកម្មវិធីអប់រំដោយរួមបញ្ចូលទាំងគោលការណ៍ណែនាំស្តីអំពីការរក្សាសុវត្ថិភាព និងព័ត៌មានស្តីពីសិទ្ធិទទួលបានការការពារពីការរំលោភបំពាន និងការកេងប្រវ័ញ្ច ។

## ៧- ការបង្កើតការយល់ដឹងចំពោះបុគ្គលិក និងអ្នកពាក់ព័ន្ធ ត្រូវមាន:

- ផែនការ ឬកម្មវិធីបណ្តុះបណ្តាលបុគ្គលិកអំពីអង្គការសុវត្ថិភាពកុមារ
- របាយការណ៍ និងបញ្ជីវត្តមានអ្នកចូលរួមវគ្គបណ្តុះបណ្តាល
- គោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាល
- ទម្រង់វាយតម្លៃការបណ្តុះបណ្តាល ។

## ៨- បញ្ជីសេវាបញ្ជូនសម្រាប់ការធ្វើអន្តរាគមន៍ ត្រូវមាន:

- ព័ត៌មានអំពីប្រភពសម្រាប់ជួយដល់កុមារ
- ព័ត៌មានទាក់ទងទៅនឹងការបណ្តុះបណ្តាល ការផ្តល់ប្រឹក្សា ការជួយគាំទ្ររបស់បុគ្គលិក ឬមនុស្សធំដែលមិនបម្រើការក្នុងអង្គការឱ្យយល់ដឹងពីរបៀបជួយកុមារ (ដូចជាខិតប័ណ្ណជាដើម)
- បញ្ជីសម្រាប់ទាក់ទង/ហៅរកអ្នកជំនាញការដើម្បីផ្តល់ជាយោបល់ និងព័ត៌មាននានា ។

### ៩- ផែនការសម្រាប់ធ្វើការចាត់ចំណាត់ប្រមាណសកម្មភាពអង្គការ ត្រូវមាន:

- រៀបរាប់ក្នុងគោលនយោបាយការពារកុមារ
- កត់ត្រា ឬសរសេរពីពេលវេលាសម្រាប់ពិនិត្យមើលការអនុវត្តគោលនយោបាយ និងអ្នកទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យ
- ការសង្ខេបពីចំនួននៃបញ្ហារំលោភបំពាន និងចំនួនពាក្យបណ្តឹង ។

**ប្រការ ៥.-**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | ជាប្រធាន |
| ២-តំណាងពីអង្គការមិនមែនរដ្ឋាភិបាល | ១ រូប | ជាអនុប្រធាន |
| ៣-តំណាងក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងងាយរងគ្រោះ | ១ រូប | ជាលេខាធិការ |
| ៤-តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបោះឆ្នោតជ្រើសតាំង ដោយអង្គការជាសមាជិក | ៦ រូប | ជាសមាជិក |
| ៥-តំណាងនាយកដ្ឋានសុខុមាលភាពកុមារ | ៣ រូប | ជាសមាជិក |
| ៦-តំណាងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | ២ រូប | ជាសមាជិក |
| ៧-តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ១ រូប | ជាសមាជិក |

ការតែងតាំងសមាសភាពគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ប្រការ ៦.-**

គណៈកម្មការវាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ ត្រូវសម្របសម្រួលការងាររបស់ខ្លួន និងសហការយ៉ាងជិតស្និទ្ធជាមួយអនុគណៈកម្មាធិការស្វែងរកការគាំទ្ររបស់ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ។

**ប្រការ ៧.-**

នាយកដ្ឋានសុខុមាលភាពកុមារមានភារកិច្ចក្នុងការចាត់ចែង ដើម្បីផ្តល់ការបណ្តុះបណ្តាលជូនស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីអង្គការសុវត្ថិភាពកុមារ ។

ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវការបណ្តុះបណ្តាលអំពីអង្គការសុវត្ថិភាពកុមារ ស្នើសុំមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីទទួលការបណ្តុះបណ្តាល ។

**ប្រការ ៨.-**

គណៈកម្មការវាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ មានភារកិច្ចចុះត្រួតពិនិត្យ និងវាយតម្លៃស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល និងលើកសំណើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចេញវិញ្ញាបនបត្រជូន ។

គំរូវិញ្ញាបនបត្រអង្គការសុវត្ថិភាពកុមារ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

គណៈកម្មការវាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមរយៈនាយកដ្ឋានសុខុមាលភាពកុមារ ។

**ប្រការ ៩.-**

វិញ្ញាបនបត្រដែលបានប្រគល់ជូនស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល មានសុពលភាពរយៈពេល ០៣ឆ្នាំ។ ក្នុងករណីដែលស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល មិនប្រតិបត្តិតាមបទប្បញ្ញត្តិដូចចែងនៅក្នុងប្រការ ៤ នៃប្រកាសនេះ គណៈកម្មការវាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបញ្ចប់ការទទួលស្គាល់ និងដកហូតវិញ្ញាបនបត្រវិញ។

**ប្រការ ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ គណៈកម្មការវាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ និងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ
- អនុគណៈកម្មាធិការស្វែងរកការគាំទ្រ
- ដូចប្រការ ៩ និងប្រការ ១១
- ឯកសារ-កាលប្បវត្តិ